00746972

E129/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 10 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007/ECCC/TC**

ចំណាត់ថ្នាក់ឯកសារ៖ **សាធារណៈ**

មន្ទីរឃុំឃាំង អ.វ.ត.ក
លេខ 303 ម.ឃ
ថ្ងៃទី 12 ខែ តុលា 2011
ម៉ោង 9:00

**ដីកាកោះខ្លួនជាប់ចោទ**

យើងចៅក្រម **និល ណុន** ជាប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) កោះហៅឈ្មោះ៖

| | |
|---|---|
| នួន ជា | ភេទ ប្រុស កើតនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩២៦ នៅភូមិ វត្តគរ ឃុំ វត្តគរ ស្រុក សង្កែ ខេត្ត បាត់ដំបង ប្រទេសកម្ពុជា |
| ខៀវ សំផន | ភេទ ប្រុស កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១ នៅឃុំ រំចេក ស្រុក រំដួល ខេត្ត ស្វាយរៀង ប្រទេសកម្ពុជា |
| អៀង ធីរិទ្ធ (ឈ្មោះដើម ខៀវ ធីរិទ្ធ) | ភេទ ស្រី កើតនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៣២ នៅសង្កាត់ លេខ ៥ ក្រុង ភ្នំពេញ ប្រទេសកម្ពុជា |
| អៀង សារី (ឈ្មោះកំណើត គឹម ត្រាំង) | ភេទ ប្រុស កើតនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩២៥ នៅឃុំ លឿងវាំ ស្រុក ត្រាវិញ ខេត្ត ត្រាវិញ វៀតណាមខាងត្បូង (កូសាំងស៊ីន) |

បច្ចុប្បន្នជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឱ្យចូលមកកាន់បន្ទប់សវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ នៅម៉ោង ៨.៣០ នាទី ព្រឹក ដើម្បីចូលរួមសវនាការស្តីពីការកំណត់ដាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

និងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ រហូតដល់សវនាការត្រូវបានផ្អាក ឬបញ្ចប់។

ជនជាប់ចោទទាំងអស់មានសិទ្ធិក្នុងការចូលរួមសវនាការស្តីពីការបញ្ជាក់អំពីទម្រង់នៃសំណាង ។ ជនជាប់-ចោទ នួន ជា ខៀវ សំផន និង អៀង សារី គឺមិនតម្រូវឱ្យមានវត្តមានក្នុងអំឡុងពេលសវនាការស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការនោះទេ លើកលែងតែជនជាប់ចោទ អៀង ធីរិទ្ធ ។

**<u>បញ្ជាក់</u>**៖ ជនជាប់ចោទនីមួយៗអាចអមមកជាមួយដោយមេធាវីរបស់ខ្លួន។

**<u>សូមជូនភ្ជាប់មកជាមួយ៖</u>**

- ដីកាកំណត់កាលបរិច្ឆេទសវនាការ ដែលនឹងត្រូវធ្វើនៅថ្ងៃទី ១៩ - ២០ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E129) ដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ។

ភ្នំពេញថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

E C C C E T C

និល ណុន

<u>ការទទួលស្គាល់អំពីការជូនដំណឹងដីកាកោះ</u>

យើងខៀវ ចយ ជាប្រធានមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពិតជាបានទទួល ដីកាកោះជនជាប់ចោទមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងបានប្រគល់ដីកាដែលបានភ្ជាប់មកជាមួយ ដល់ជនជាប់ចោទពិតប្រាកដមែន។

ភ្នំពេញ ថ្ងៃទី 12 ខែតុលា ឆ្នាំ ២០១១

ប្រធានមន្ទីរឃុំឃាំង

ខៀវ-ចយ